# ចែករំលែកចំណេះដឹងនៃបទពិសោធន៍

# SHARE EXPERIENCE KNOWLEDGE

## សម្រង់ពាក្យសំខាន់ៗ
**(Useful Quotes)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : ភាពជាអ្នកមានគតិបណ្ឌិត

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ២១ មេសា ២០១២

សម្រង់ពាក្យ ចែកបន្តដោយ (Quotes shared on by) : លោក សៀង ប៊ូហៀង

០១. អនាគតរបស់យើង គឺពឹងផ្អែកទាំងស្រុងទៅលើគុណភាពនៃការគិតរបស់យើង ។

០២. របកគំហើញដ៏ធំធេងនៃជំនាន់យើង គឺមនុស្សអាចផ្លាស់ប្តូរជីវិតរបស់ខ្លួនតាមរយៈការផ្លាស់ប្តូរចិត្តគំនិតរបស់គេ ។

០៣. ការអប់រំជាស្ពានឆ្ពោះទៅកាន់ភាពជោគជ័យ ហើយការអប់រំមិនមែនចប់ត្រឹមបានទទួលសញ្ញាប័ត្រចុងក្រោយទេ ។

០៤. បើអ្នកគិតថា ការអប់រំតំរូវឱ្យអ្នកចំណាយលុយច្រើន ចូរអ្នកសាកល្បងធ្វើជាមនុស្សល្ងង់ នុំះអ្នកនឹងដឹងថា អ្នកត្រូវចំណាយ លុយទៅលើភាពល្ងង់នោះ ច្រើនជាងការចំណាយទៅលើការអប់រំរបស់អ្នកទៅទៀត ។

០៥. ធ្វើកិច្ចការអ្វី ត្រូវហ៊ានទទួលខុសត្រូវ ហើយត្រូវអនុវត្តឱ្យបានល្អប្រសើរ ។

០៦. ធ្វើការអ្វីមួយ បើខ្លាចពាក្យទិះទៀនពីអ្នកដទៃ ការនោះពិតជាមិនបានល្អ ហើយមិនបានសំរេចឡើយ ។

០៧. អ្នកឈ្នះមិនដែលបោះបង់ អ្នកបោះបង់មិនដែលឈ្នះ ។

០៨. មិនចាំបាច់ឱ្យគេរហ័សស្គាល់យើងពេកទេ ក៏មិនចាំបាច់ឱ្យគេគោរពយើង ក្នុងពេលដែលយើងនៅខ្ចីនៅឡើយដែរ ។ យើងគិត តែពីរៀបចំចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិឱ្យស្រួលបួលទៅ គេនឹងគោរព ហើយទទួលស្គាល់យើងជាមិនខាន ។

០៩. ចង់ឱ្យគេស្រលាញ់យើង ស្តាប់បង្គាប់យើង ប្រការពិសេសត្រូវប្រយត្ន័ពាក្យសំដី ត្រូវមានធម៌មេត្តា និងត្រូវវាងវៃ ។

១០. ធ្វើធំត្រូវចេះអត់ធ្មត់រឿងតូចៗ ដើម្បីជាប្រយោជន៍សំរាប់រឿងធំ ។

១១. ប្រាជ្ញាមនុស្សពុំមានដែនកំណត់ទេ លុះត្រាតែយើងទទួលស្គាល់ថាមាន ។

១២. ការឱ្យតំលៃខ្លួនឯង ធ្វើឱ្យមានភាពថ្លៃថ្នូរក្នុងអារម្មណ៍ ដែលជាបុព្វហេតុនៃភាពរឹងមាំដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយ ។

១៣. រទេះមិនអាចធ្វើចលនាលឿនជាងសេះដែលកំពុងអូសវាទេ រីឯមនុស្សម្នាក់វិញ ក៏មិនអាចបំពេញការងារឱ្យបានល្អជាង ការឱ្យតម្លៃចំពោះខ្លួនឯងដែរ ។

១៤. មិនត្រូវបណ្ដោយខ្លួនឱ្យប្រែប្រួលទៅតាមមនោសញ្ចេតនាឡើយ
ត្រូវខំធ្វើជាម្ចាស់លើខ្លួនឯងឱ្យបានគ្រប់ពេលវេលា។
១៥. នៅពេលមានឧបសគ្គមករារាំង យើងមិនត្រូវភ័យ ឬស្លន់ទេ យើងត្រូវប្រឹងប្រែង អត់ធន់ ពុះពារទម្លាយឧបសគ្គនោះ។
១៦. កុំខឹងផ្ដេសផ្ដាស់ ទោះបីក្នុងករណីគួរខឹងក៏ដោយ ត្រូវប្រើសំដីឱ្យបានធម្មតា នុះអ្នកមុខតែអាចអូសទាញបេះដូងគេបាន។
១៧. ពេលត្រូវគេនិយាយសំអុយមួលបង្កាច់ យើងមិនត្រូវច្រឡោតតោកតូង ប្រកែកប្រណាំងរកឫសរកគល់ រកខុសរកត្រូវ នោះទេ គឺយើងត្រូវធ្វើឱ្យនឹងធឹង ឬនៅស្ងៀមក៏បានដែរ រួចរកដំណោះស្រាយដ៏ប្រសើរ ដើម្បីទទួលបាននូវជ័យជំនះ។
១៨. ខ្លួនយើងអាចជាសត្រូវទីមួយរបស់យើង ប្រសិនបើយើងបណ្ដែតបណ្ដោយវា។
១៩. ការជឿតែលើខ្លួនឯងម្នាក់ ចេះគោរពតែខ្លួនឯង នុះមានន័យថាយើងកំពុងតែធ្វើដំណើរនៅក្នុងផ្លូវមហាវង្វេងហើយ។
២០. ស្រឡាញ់ ផឹកទឹកទន្លេក៏ផ្អែម តែបើស្អប់ ស៊ីអំពៅក៏ជូរ។
២១. ធាតុពិតទាំងបួននៃធម៌របស់ព្រះពុទ្ធគឺ ពិតជាមានទុក្ខ ពិតជាមានហេតុនៃទុក្ខ ពិតជាមានភាពរលត់ទុក្ខ និងពិតជាមានផ្លូវ ទៅកាន់ភាពរលត់ទុក្ខ។
២២. សត្វត្រចៀកកម្មមួយ មិនអាចធ្វើជារដូវរំហើយបានឡើយ។
២៣. អ្នកដែលចេះផ្ដល់ឱវាទដល់អ្នកដទៃ មិនមែនសុទ្ធតែអាចអនុវត្តតាម នូវរាល់ពាក្យសំដីដែលខ្លួនបានទូន្មានគេនោះទេ។
២៤. ការប្រាស្រ័យទាក់ទងល្អ គឺជាគន្លឹះដែលនាំឱ្យយើងទទួលបាននូវជោគជ័យ។
២៥. ដើម្បីពង្រីកការរាប់អានឱ្យបានងាយ យើងត្រូវចេះនិយាយឱ្យពិរោះ ត្រូវចេះស្ដាប់គេនិយាយ ត្រូវចេះសរសើរជាងទិះទៀន ហើយមិនត្រូវនិយាយរឿងរបស់ខ្លួនឱ្យគេស្ដាប់ច្រើនពេកទេ។
២៦. បើយើងយល់ថា ការនិយាយច្រើននាំឱ្យខ្លួនថោក ហើយគេមិនចូលចិត្ត យើងគប្បីនៅស្ងៀម បន្ធូរបន្ថយការនិយាយច្រើន តែគេមិនឱ្យយើងធ្វើគទេ។
២៧. យើងស្រេកឃ្លាននូវការទទួលយល់ព្រមខ្លាំងប៉ុនណា យើងក៏ភ័យខ្លាចចំពោះការស្ដីបន្ទោសខ្លាំងប៉ុណ្ណោះដែរ។
២៨. ភាគច្រើន មនុស្សដែលយើងនឹងស្ដីបន្ទោស ប្រាកដជានិយាយការពារខ្លួនឯង ហើយបន្ទោសយើងវិញមិនខាន។
២៩. យើងគប្បីបង្កើតជំលោះមានប្រយោជន៍ ជៀសវាងជំលោះឥតប្រយោជន៍។
៣០. ពេលខ្លះមនុស្សយើងទំរាំតែដឹងខ្លួនខុស ថាខុសជ្រុលទៅហើយ ដូច្នេះមានតែយកកំហុសនោះមកធ្វើជាមេរៀនទេ។
៣១. នៅពេលអនុវត្តកិច្ចការអ្វីមួយ យើងត្រូវគិតថាខ្លួនយើងមានសត្រូវច្រើនជាងមិត្ត។
៣២. ក្នុងការរស់នៅរបស់អ្នករាល់ថ្ងៃ អ្នកត្រូវលៃលកពេលខ្លះសម្រាប់ពិនិត្យមើលសំដីនិយាយ ចិត្តគំនិត និងអាកប្បកិរិយា ដែលអ្នកបានធ្វើ ឬប្រព្រឹត្តកន្លងមក។

៣៣. មនុស្សមានយោបល់ទើបនិយាយចេញ ប៉ុន្តែមនុស្សនៅស្ងៀមក៏មិនមែនឥតប្រយោជន៍ដែរ ។
៣៤. មនុស្សគមិនចេះនិយាយ ប៉ុន្តែមនុស្សចេះនិយាយ ជូនកាលគេធ្វើគ ។
៣៥. មនុស្សមួយចំនួន នៅស្ងៀមពីព្រោះគេយល់ គេធ្វើម្ចាស់លើខ្លួនឯងបាន ដល់ពេលគេនិយាយ គេនិយាយសុទ្ធតែត្រូវ ។
៣៦. យើងចេះទ្រាំទ្រនឹងការយល់ច្រឡំរបស់មនុស្ស គឺជាការល្អមួយហើយ ប៉ុន្តែដើម្បីឱ្យកាន់តែល្អប្រសើរថែមទៀត យើងត្រូវ ជៀសវាងនូវអំពើណាដែលនាំឱ្យគេយល់ច្រឡំ ។
៣៧. មិត្តភាព គឺការដែលមានចិត្តសណ្ដោសគ្នាទៅវិញទៅមក វាលេចឡើងដោយលទ្ធផល ។
៣៨. ប្រការជាធម្មជាតិល្អជាងគេបំផុត ដែលមនុស្សមានបន្ទាប់ពីខ្លួនពេញវ័យមក គឺសេចក្ដីស្នេហាមិត្តសំឡាញ់ ។
៣៩. មិត្តសំឡាញ់ស្មោះត្រង់ គឺជាវត្ថុសម្រាប់ការពារដ៏រឹងមាំ ។
៤០. គេត្រូវស្ទង់ជម្រៅទន្លេមុននឹងគេចុះទឹក គេត្រូវស្ទង់ចិត្តមនុស្ស មុននឹងដាក់ជំនឿលើអ្នកនោះ ។
៤១. ជីវិតមនុស្សយើង មិនមែនខ្លីដល់ថ្នាក់យើងលែងយកចិត្តទុកដាក់នឹងការរស់នៅឡើយ ។
៤២. ការស្គាល់គុណស្រ័យ គឺជាអនុស្សាវរីយ៍នៃបេះដូង ។
៤៣. គុណអាស្រ័យដែលធ្វើជាមួយមនុស្សកតញ្ញូ ប្រៀបដូចជាការដាប់ឆ្លាក់នៅលើផ្ទាំងសិលា តែបើធ្វើជាមួយអសប្បុរសជនវិញ ប្រៀបដូចជាការគូសវាសនៅលើផ្ទៃទឹកអញ្ចឹង ។
៤៤. គ្រូពេទ្យដែលព្យាបាលខ្លារបួសនឹងក្លាយជាចំណីរបស់ខ្លា ។
៤៥. សំរាកអត់ធ្វើអី គឺសំរាប់តែមនុស្សស្លាប់បណ្ដោះ ។
៤៦. បុគ្គលដែលពុំបានប្រព្រឹត្តខុសច្បាប់ មិនចាំបាច់ញាប់ញ័រនៅទីកន្លែងដែលមានច្បាប់ទេ ។
៤៧. មធ្យោបាយតែមួយគត់សំរាប់ឱ្យយើងគេចផុតពីសាលក្រមតុលាការ គឺត្រូវដាក់ខ្លួននៅក្រោមភាពផ្ដាច់ការនៃច្បាប់ ។